# ក្រសួងលំនៅដ្ឋាន និងអភិវឌ្ឍន៍ក្រុងសហរដ្ឋអាមេរិក

## ការិយាល័យលំនៅដ្ឋានសាធារណៈ និងឥណ្ឌា

## បំណុលជំពាក់ទីភ្នាក់ងារលំនៅដ្ឋានរដ្ឋ និងការបញ្ឈប់

**កំណត់សម្គាល់អំពីការកាត់បន្ថយការងារឯកសារ៖** បន្ទុករៀបចំរបាយការណ៍សាធារណៈសម្រាប់ការប្រមូលព័ត៌មាននេះត្រូវបានប៉ាន់ស្មានថាជាមធ្យមត្រូវចំណាយពេល 7 នាទីសម្រាប់មួយចម្លើយ។ ចំនួននេះរួមបញ្ចូលទាំងពេលវេលាសម្រាប់អ្នកផ្តល់ចម្លើយអានឯកសារ និងធ្វើការបញ្ជាក់ក៏ដូចជាបន្តការរក្សាទុកឯកសារផងដែរ។ ព័ត៌មាននេះនឹងត្រូវប្រើប្រាស់នៅក្នុងដំណើរការជួល។
ការឆ្លើយតបចំពោះសំណើសុំព័ត៌មាននេះចាំបាច់ ត្រូវទទួលបានអត្ថប្រយោជន៍។ ទីភ្នាក់ងារមិនអាចប្រមូលព័ត៌មាននេះឡើយ ហើយអ្នកមិនត្រូវបានកំណត់ឲ្យបំពេញសំណុំបែបបទនេះទេ លុះត្រាតែសំណុំបែបបទនេះបង្ហាញលេខគ្រប់គ្រងOMB ដែលមានសុពលភាព។ លេខ OMB គឺ 2577-0266, និងអស់សុពលភាពនៅថ្ងៃទី08/31/2016 ។

**ការជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំ និងអ្នកចូលរួមក្នុងកម្មវិធីជំនួយជួលផ្ទះរបស់ HUD ដូចខាងក្រោម៖AMS:**

- លំនៅដ្ឋានរដ្ឋ (24 CFR 960)
- លិខិតបញ្ជាក់ជម្រើសលំនៅដ្ឋានផ្នែកទី 8 រួមទាំងកម្មវិធីជំនួយលំនៅដ្ឋានគ្រោះមហន្តរាយ (24 CFR 982) ការស្តារឡើងវិញកម្រិតមធ្យម
- ផ្នែកទី 8 (24 CFR 882)
- លិខិតបញ្ជាក់ដោយផ្អែកលើគម្រោង (24 CFR 983)

ក្រសួងលំនៅដ្ឋាន និងអភិវឌ្ឍន៍ក្រុងសហរដ្ឋអាមេរិករក្សាទុកនូវឃ្លាំងបំណុលជាតិដែលជំពាក់ទីភ្នាក់ងារលំនៅដ្ឋាន (PHAs) ឬម្ចាស់អចលនទ្រព្យផ្នែកទី 8 និងព័ត៌មានជំទាស់របស់អ្នកចូលរួមពីមុនៗដែលបានបញ្ឈប់ការចូលរួមកម្មវិធីជំនួយជួលផ្ទះរបស់ HUD ដែលបានលើកឡើងខាងលើ។ ព័ត៌មាននេះត្រូវបានរក្សាទុកនៅក្នុងប្រព័ន្ធផ្ទៀងផ្ទាត់ចំណូលសហគ្រាសរបស HUD ដែលប្រើប្រាស់ដោយទីភ្នាក់ងារលំនៅដ្ឋានរដ្ឋ(PHAs) និងភ្នាក់ងារគ្រប់គ្រងរបស់ស្ថាប័ននេះដើម្បីធ្វើការផ្ទៀងផ្ទាត់ព័ត៌មានអំពីការងារ និងប្រាក់ចំណូលរបស់អ្នកចូលរួមកម្មវិធីពមទាំងដើម្បីកាត់បន្ថយកំហុសផ្នែករដ្ឋបាល និងផ្នែកទូទាត់ជំនួយលើការជួល។ ប្រព័ន្ធ EIV ត្រូវបានរៀបចំឡើងដើម្បីជួយដល់ PHAs និង HUDនៅក្នុងការធានាថាគ្រួសារមានសិទ្ធិចូលរួមនៅក្នុងកម្មវិធីជំនួយលើការជួលរបស់ HUD និងកំណត់ចំនួនត្រឹមត្រូវនៃជំនួយលើការជួលដែលគ្រួសារមានសិទ្ធិទទួលបាន។PHAទាំងអស់ត្រូវបានកំណត់ឲ្យប្រើប្រព័ន្ធនេះស្របទៅតាមបទប្បញ្ញត្តិHUD ត្រង់ចំណុច 24 CFR 5.233។

HUD តម្រូវឲ្យ PHA ដែលគ្រប់គ្រងកម្មវិធីលំនៅដ្ឋានជួលដែលបានរៀបរាប់ខាងលើ ដើម្បីរាយការណ៍អំពីព័ត៌មានជាក់លាក់នៅចុងបញ្ចប់នៃការចូលរួមរបស់អ្នកនៅក្នុងកម្មវិធីជំនួយលើការជួលរបស់ HUD។ ការជូនដំណឹងនេះផ្តល់ជូនអ្នកនូវព័ត៌មានអំពីថាតើព័ត៌មានណាខ្លះដែល PHA ចាំបាច់ត្រូវផ្តល់ជូន HUD ដែលជាស្ថាប័នមានសិទ្ធិទទួលបានព័ត៌មាននេះ របៀបប្រើប្រាស់ព័ត៌មាននេះ និងសិទ្ធិរបស់អ្នក។ PHA ចាំបាច់ត្រូវផ្តល់លិខិតជូនដំណឹងនេះដល់អ្នកដាក់ពាក្យស្នើសុំ និងអ្នកចូលរួមកម្មវិធីទាំងអស់ ហើយអ្នកចាំបាច់ត្រូវទទួលស្គាល់អំពីការទទួលបានលិខិតជូនដំណឹងនេះដោយចុះហត្ថលេខានៅលើទំព័រទី 2។ សមាជិកគ្រួសារម្នាក់ៗដែលជានីតិជនត្រូវតែចុះហត្ថលេខានៅលើសំណុំបែបបទនេះ។

**តើមានព័ត៌មានអ្វីខ្លះអំពីអ្នក និងការជួលផ្ទះរបស់អ្នកដែល HUD ប្រមូលពី PHA?**
ព័ត៌មានខាងក្រោមត្រូវបានប្រមូលពីសមាជិកគ្រួសាររបស់អ្នកម្នាក់ៗ (សមាសភាពគ្រួសារ)៖ ឈ្មោះពេញ ថ្ងៃខែឆ្នាំកំណើត និងលេខសន្តិសុខសង្គម។

ព័ត៌មានជំទាស់ខាងក្រោមត្រូវប្រមូលនៅពេលការចូលរួមរបស់អ្នកនៅក្នុងកម្មវិធីលំនៅដ្ឋានត្រូវបានបញ្ចប់ ទោះជាអ្នកបានស្ម័គ្រចិត្តឬមិនស្ម័គ្រចិត្តចាកចេញពីចំណែកអគារដែលបានជួយឧបត្ថម្ភក៏ដោយ:

1. ចំនួនទឹកប្រាក់នៅសល់ ដែលអ្នកជំពាក់ PHA ឬម្ចាស់ផ្ទះផ្នែកទី 8 (រហូតដល់ចំនួន $500,000) និងសេចក្តីពន្យល់អំពីទឹកប្រាក់នៅសល់ ដែលជំពាក់ (ដូចជា ថ្លៃឈ្នួលផ្ទះមិនទាន់បានបង់ ថ្លៃប្រតិសកម្ម (ដោយសារប្រាក់ចំណូលមិនបានរាយការណ៍ និង/ឬ ការផ្លាស់ប្តូរសមាសភាពគ្រួសារ) ឬការចំណាយប្រាក់ផេសងៗទៀតដូចជា ការខូចខាតការបង់ប្រាក់ថ្លៃសេវាសាធារណៈជាដើម) និង
2. ថាតើអ្នកបាន ឬមិនបានបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងទូទាត់សំណង សម្រាប់ចំនួនទឹកប្រាក់ ដែលអ្នកជំពាក់ PHA និង
3. ថាតើអ្នកបាន ឬមិនបានរំលោភលើកិច្ចព្រមព្រៀងទូទាត់សំណង និង
4. ថាតើ PHA បានឬមិនបានទទួលបានការដីកាសម្រេចប្រឆាំងនឹងអ្នក និង
5. ថាតើអ្នកបាន ឬមិនបានដាក់ពាក្យប្រកាសក្ស័យធន និង
6. មូលហេតុអវិជ្ជមានសម្រាប់ការបញ្ចប់ការចូលរួមរបស់អ្នក ឬស្ថានភាពអវិជ្ជមានណាមួយ (ដូចជា ចំណែកអគារដែលបានបោះបង់ ការក្លែងបន្លំ ការបំពានកិច្ចសន្យាជួល សកម្មភាពល្មើសផេសងៗជាដើម) គិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការចូលរួម។

**តើនរណាខ្លះមានសិទ្ធិចូលមើលព័ត៌មានដែលបានប្រមូល?**
ព័ត៌មាននេះនឹងត្រូវប្រគល់ជូនបុគ្គលិក HUD បុគ្គលិក PHA និងអ្នកជាប់កិច្ចសន្យារបស់ HUD និង PHA។

**តើព័ត៌មាននេះនឹងត្រូវប្រើប្រាស់យ៉ាងដូចម្តេច?**
PHA នឹងទទួលបានព័ត៌មាននេះនៅពេលដាក់ពាក្យស្នើសុំជំនួយលើការជួល ឬពិនិត្យឡើងវិញលើប្រាក់ចំណូល និងសមាសភាពគ្រួសារសម្រាប់អ្នកចូលរួមដែលមានស្រាប់។ PHA នឹងអាចចូលមើលព័ត៌មាននេះដើម្បីកំណត់អំពីភាពសមស្របរបស់គ្រួសារក្នុងការបន្តទទួលជំនួយលើការជួល និងជៀសវាងការផ្តល់ជំនួយលំនៅដ្ឋានសហព័ន្ធមានកំណត់ដល់គ្រួសារដែលពីមុនមិនអាចអនុវត្តតាមលក្ខខណ្ឌកម្មវិធីរបស់ HUD។ ប្រសិនបើព័ត៌មានដែលបានរាយការណ៍មានភាពត្រឹមត្រូវ PHA អាចបញ្ឈប់ជំនួយលើការជួលបច្ចុប្បន្នរបស់អ្នក និងបដិសេធសំណើសុំជំនួយលើការជួល HUDនាពេលអនាគតរបស់អ្នក ស្របទៅតាមគោលការណ៍របស់ PHA។

**តើព័ត៌មានអំពីបំណុលដែលជំពាក់ និងការបញ្ឈប់ត្រូវរក្សាទុកនៅក្នុង EIVរយៈពេលប៉ុន្មាន?**
ព័ត៌មានអំពីបំណុលដែលជំពាក់ និងការបញ្ឈប់នឹងត្រូវរក្សាទុកនៅក្នុង EIV រយៈពេលរហូតដល់ដប់ (10) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទបញ្ឈប់ការចូលរួម។

**តើខ្ញុំមានសិទ្ធិអ្វីខ្លះ?**
យោងទៅតាមច្បាប់ឯកជនភាពរបស់សហព័ន្ធឆ្នាំ 1974 ដូចដែលបានធ្វើវិសោធនកម្ម (5 USC 552a) និងបទប្បញ្ញត្តិ HUD ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ឯកជនភាពរបស់សហព័ន្ធឆ្នាំ 1974 (24 CFR ផ្នែកទី16) អ្នកមានសិទ្ធិដូចខាងក្រោម៖
1. មានសិទ្ធិចូលមើលកំណត់ត្រារបស់អ្នកដែលរក្សាទុកដោយ HUD ស្របទៅតាម 24 CFR ផ្នែក16។
2. ពិនិត្យមើលផ្នែករដ្ឋបាលទៅលើការបដិសេធរបស់ HUD ចំពោះសំណើរបស់អ្នកក្នុងការចូលមើលកំណត់ត្រារបស់អ្នកដែលរក្សាទុកដោយ HUD។
3. ស្នើឲ្យកែតម្រូវព័ត៌មានមិនត្រឹមត្រូវនៅក្នុងកំណត់ត្រារបស់អ្នកនៅពេលធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរ។
4. ដាក់សំណើសុំប្តឹងទាស់ទៅនឹងការកំណត់ជំទាស់ដំបូងទៅលើសំណើសុំកែតម្រូវ ឬកែសម្រួលកំណត់ត្រានៅក្នុងរយៈពេល 30 ថ្ងៃប្រតិទិនបន្ទាប់ពីចេញការបដិសេធជាលាយលក្ខណ៍អក្សរ។
5. ស្នើឲ្យបង្ហាញកំណត់ត្រារបស់អ្នកដល់ភាគីទីបីនៅពេលទទួលបានសំណើជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខារបស់អ្នក។

**តើខ្ញុំត្រូវធ្វើដូចម្តេចប្រសិនបើខ្ញុំតវ៉ាចំពោះព័ត៌មានអំពីបំណុល ឬការបញ្ឈប់ដែលបានរាយការណ៍អំពីខ្ញុំ?**
ប្រសិនបើអ្នកមិនយល់ស្របចំពោះព័ត៌មានដែលបានរាយការណ៍ អ្នកគួរទាក់ទងជាលាយលក្ខណ៍អក្សរទៅ PHA ដែលបានរាយការណ៍ព័ត៌មាននេះអំពីអ្នក។ ឈ្មោះ អាសយដ្ឋាន និងលេខទូរសព្ទរបស់ PHA មានបង្ហាញជូននៅលើរបាយការណ៍អំពីបំណុលដែលជំពាក់ និងការបញ្ឈប់។
អ្នកមានសិទ្ធិស្នើសុំ និងទទួលបានរបាយការណ៍នេះមួយច្បាប់ពី PHA។ សូមប្រាប់ PHA អំពីមូលហេតុដែលអ្នកធ្វើការជំទាស់ទៅនឹងព័ត៌មាន និងផ្តល់ឯកសារដែលជាអំណះអំណាងអំពីការជំទាស់របស់អ្នក។ គោលការណ៍រក្សាទុកកំណត់ត្រារបស់ HUD នៅត្រង់ចំណុច 24 CFR ផ្នែកទី 908 និង 24 CFR ផ្នែកទី 982 ចែងថា PHA អាចបំផ្លាញចោលកំណត់ត្រារបស់អ្នកនៅក្នុងរយៈពេលបីឆ្នាំគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការចូលរួមរបស់អ្នកនៅក្នុងកម្មវិធី។ ដើម្បីធានាថា កំណត់ត្រារបស់អ្នកនៅមានក្នុងការរក្សាទុក ការជំទាស់ទៅនឹងព័ត៌មានអំពីបំណុល ឬការបញ្ឈប់ដំបូងត្រូវធ្វើឡើងនៅក្នុងរយៈពេលបីឆ្នាំគិតចាប់ពីកាលបរិច្ឆេទបញ្ឈប់ការចូលរួម បើពុំដូច្នោះទេ ព័ត៌មានអំពីបំណុល និងការបញ្ឈប់នឹងត្រូវចាត់ទុកថា ត្រឹមត្រូវ។ មានតែ PHA ដែលបានរាយការណ៍ព័ត៌មានជំទាស់អំពីអ្នកប៉ុណ្ណោះដែលអាចលុបចោល ឬកែតម្រូវកំណត់ត្រារបស់អ្នក។
ការដាក់ពាក្យប្រកាសក្ស័យធនរបស់អ្នកមិននាំឲ្យមានការលុបចោលព័ត៌មានអំពីបំណុលនៅជំពាក់ ឬការបញ្ឈប់ពីប្រព័ន្ធEIV របស់ HUD ឡើយ។ ទោះបីយ៉ាងណា ប្រសិនបើអ្នកដាក់បញ្ចូលបំណុលនេះទៅក្នុងការប្រកាសក្ស័យធនរបស់អ្នក និង/ឬ បំណុលនេះត្រូវបានលុបចោលដោយតុលាផ្នែកក្ស័យធន នោះកំណត់ត្រារបស់អ្នកនឹងត្រូវធ្វើបច្ចុប្បន្នកម្មដើម្បីដាក់បញ្ចូលសូចនាករក្ស័យធននៅពេលអ្នកផ្តល់ជូនឯកសារអំពីស្ថានភាពក្ស័យធនរបស់អ្នកដល់ PHA។
PHA នឹងជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរអំពីសកម្មភាពរបស់ខ្លួនពាក់ព័ន្ធនឹងការជំទាស់របស់អ្នកនៅក្នុងរយៈពេល 30 ថ្ងៃគិតចាប់ពីថ្ងៃបានទទួលការជំទាស់ជាលាយលក្ខណ៍អក្សររបស់អ្នក។ ប្រសិនបើ PHA កំណត់ថា ព័ត៌មានដែលបានជំទាស់មិនត្រឹមត្រូវ នោះ PHA នឹងធ្វើបច្ចុប្បន្ន ឬលុបចោលកំណត់ត្រា។ ប្រសិនបើ PHA កំណត់ថា ព័ត៌មានដែលបានជំទាស់ត្រឹមត្រូវ នោះ PHA នឹងផ្តល់ជូនសេចក្តីពន្យល់អំពីអំណះអំណាងដែលថាព័ត៌មាននោះត្រឹមត្រូវ។

| **លិខិតជូនដំណឹងនេះត្រូវបានផ្តល់ជូនដោយ PHA ដែលបានបង្ហាញជូនខាងក្រោម៖** | **ខ្ញុំបាទ/នាងខ្ញុំសូមទទួលស្គាល់ថា PHA បានផ្តល់ជូនខ្ញុំនូវ*លិខិតជូនដំណឹងអំពីបំណុលដែលជំពាក់ PHA & ការបញ្ឈប់:*** |
|---|---|
| | **ហត្ថលេខា** **កាលបរិច្ឆេទ** |
| | **ឈ្មោះជាអក្សរពុម្ព** |